№ 45
08-12-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

******

ឆ្នាំទី ៥ លេខ ៤៥ ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

...ចេញពីទីស្តីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្តាហ៍

ក

មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១-១២-១៩៩៧ -ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៦៤ តែងតាំងឯកឧត្តម នៅ សំ ជាឧត្តមសេនិយទោ និង ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ ២៥៧៤

១-១២-១៩៩៧ -ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៦៥ តែងតាំងឯកឧត្តម នួន សារ៉េត ជាអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម ២៥៧៥

១-១២-១៩៩៧ -ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៦៦ តែងតាំងឯកឧត្តមឧត្តមសេនិយត្រី អ៊ៅ សុផាន់ ជានាយរងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២ ២៥៧៦

២-១២-១៩៩៧ -ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៦៧ តែងតាំងឯកឧត្តម ស៊ុយ ម៉ុងលាង ជានាយកខុទ្ទកាល័យឯកឧត្តម អ៊ឹង ហួត ២៥៧៧

២-១២-១៩៩៧ -ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៦៨ តែងតាំងលោក ណូ សម្បុក ជានាយកពិធីការឯកឧត្តម អ៊ឹង ហួត ២៥៧៨

២-១២-១៩៩៧ -ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៦៩ តែងតាំងលោក ម៉ា ជិន ជាទីប្រឹក្សា បន្ថែមលើមុខងារបច្ចុប្បន្ន ជានាយករងខុទ្ទកាល័យឯកឧត្តម អ៊ឹង ហួត ២៥៧៩

២-១២-១៩៩៧ -ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៧០ តែងតាំងលោក កេន សូភិន ជាទីប្រឹក្សាឯកឧត្តម អ៊ឹង ហួត ២៥៨០

II. រាជរដ្ឋាភិបាល

១-១២-១៩៩៧ អនុក្រឹត្យលេខ ៧៨ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ២៥៨១

២-១២-១៩៩៧ -អនុក្រឹត្យលេខ ៧៩ អនក្រ.បក ស្តីពីការបង្កើតក្រុមដឹកនាំការងារកម្មវិធីសីលា ២៥៩១

៣-១២-១៩៩៧	-អនុក្រឹត្យលេខ ៨០ អនក្រ.បក ស្ដីពីការឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ១៩៩៨	២៥៩៤
១-១២-១៩៩៧	-អនុក្រឹត្យលេខ ២៣០ អនក្រ.តត ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ	២៥៩៦
១-១២-១៩៩៧	-អនុក្រឹត្យលេខ ២៣១ អនក្រ.តត ស្ដីពីការបំពាក់ឋានន្តរសក្កិជូនដល់នាយនគរបាលជាតិ	២៥៩៧
២-១២-១៩៩៧	-អនុក្រឹត្យលេខ ២៣២ អនក្រ.តត ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ	២៦០០
២-១២-១៩៩៧	-អនុក្រឹត្យសលខ ២៣៣ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ	២៦០១
៥-១២-១៩៩៧	-អនុក្រឹត្យលេខ ២៣៤ អនក្រ.តត ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ	២៦០២
៥-១២-១៩៩៧	-អនុក្រឹត្យលេខ ២៣៥ អនក្រ.តត ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ	២៦០៣
៥-១២-១៩៩៧	-អនុក្រឹត្យលេខ ២៣៦ អនក្រ.តត ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ	២៦០៤
៥-១២-១៩៩៧	-អនុក្រឹត្យលេខ ២៣៧ អនក្រ.តត ស្ដីពីការជូនមេដាយ សហមេត្រី	២៦០៦
៥-១២-១៩៩៧	-អនុក្រឹត្យលេខ ២៣៨ អនក្រ.តត ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ	២៦០៧
៥-១២-១៩៩៧	-អនុក្រឹត្យលេខ ២៣៩ អនក្រ.តត ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ	២៦០៨
៨-១២-១៩៩៧	-អនុក្រឹត្យលេខ ២៤០ អនក្រ.តត ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ	២៦០៩
៨-១២-១៩៩៧	-អនុក្រឹត្យលេខ ២៤១ អនក្រ.តត ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ	២៦១០
៨-១២-១៩៩៧	-អនុក្រឹត្យលេខ ២៤២ អនក្រ.តត ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ	២៦១១
៨-១២-១៩៩៧	-អនុក្រឹត្យលេខ ២៤៣ អនក្រ.តត ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ	២៦១២
៨-១២-១៩៩៧	-អនុក្រឹត្យលេខ ២៤៤ អនក្រ.តត ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ	២៦១៣
៨-១២-១៩៩៧	-អនុក្រឹត្យលេខ ២៤៥ អនក្រ.តត ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ	២៦១៧
៨-១២-១៩៩៧	-អនុក្រឹត្យលេខ ២៤៦ អនក្រ.តត ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ	២៦១៨

III- ការងារបណ្ដាក្រសួង

១-ទីស្ដីការគណៈរដ្ឋមន្ត្រី

ប្រកាស

០២-១២-១៩៩៧	ប្រកាសលេខ ១៥៩ ប្រក. ស្ដីពីការតែងតាំងមន្ត្រីរាជការ	២៦១៩
០៤-១២-១៩៩៧	ប្រកាសលេខ ១៦១ ប្រក.បល ស្ដីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	២៦២០

[illegible]-១២-១៩៩៧	ប្រកាសលេខ ១៦២ ប្រក.បល ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	២៦២១

២.ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

ប្រកាស

០១-១២-១៩៩៧	ប្រកាសលេខ ៣៩៥ ពណ៌បលក្រប ស្តីពីការបង្កើតមន្ទីរពាណិជ្ជកម្មក្រុងប៉ៃលិន	២៦២២

៣.ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

ប្រកាស

០១-១២-១៩៩៧	ប្រកាសលេខ ៨០៤ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ ភ្នំជីសូ ទៅជាអនុវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន "ភ្នំជីសូ"	២៦២៤
០១-១២-១៩៩៧	ប្រកាសលេខ ៨០៥ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ ព្រៃនប់ ទៅជាអនុវិទ្យាល័យ ហ៊ុន សែន "ព្រៃនប់"	២៦២៥
០១-១២-១៩៩៧	ប្រកាសលេខ ៨០៦ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ អង្គរបូរី ទៅជាវិទ្យាល័យ "អង្គរបូរី"	២៦២៧
០១-១២-១៩៩៧	ប្រកាសលេខ ៨០៧ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យទំពមានជ័យ	២៦២៨
០១-១២-១៩៩៧	ប្រកាសលេខ ៨០៨ អយក.ប្រក ស្តីពីការប្តូរឈ្មោះវិទ្យាល័យ បល្លង្គ ទៅជាវិទ្យាល័យ ជា ស៊ីម កំពង់ថ្ម	២៦៣០
០១-១២-១៩៩៧	ប្រកាសលេខ ៨០៩អយក.ប្រក ស្តីពីការពង្រីកនិងប្តូរឈ្មោះអនុវិទ្យាល័យ ចំបក់ ទៅជាវិទ្យាល័យ ហ៊ុន សែន "ចំបក់"	២៦៣១

៤.ទីស្តីការរដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ

ប្រកាស

០៤-១២-១៩៩៧	ប្រកាសលេខ ២០៧៤ ប្រក.អ.ជ.ប ស្តីពីការតែងតាំងមន្ត្រីរាជការសំរាប់តំណែងតំណាងធនាគារអភិវឌ្ឍន៍អាស៊ី	២៦៣៣

៥.រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

០២-១២-១៩៩៧	សេចក្តីសំរេចលេខ ៦៦០ សសរ.មស.ក្រខ ស្តីពីការបែងចែកនិស្សិតចំនួន ០៤នាក់ ដែលទើបបញ្ចប់ការសិក្សាពីបរទេស	២៦៣៥

I- ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ នស/រកត/១១៩៧/២៦៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តមឧត្តមសេនីយ៍ទោ **នៅ សំ** ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ មានឋានៈ ស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និង តាមព្រះរាជ[illegible]ង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៦៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តម **នួន សារ៉េត** ជាឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណៈរដ្ឋសង្គមនិយមវៀតណាម ជំនួសឯកឧត្តម **មាស ស៊ិប**។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៦៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា.

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧.

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តមឧត្តមសេនីយ៍ត្រី **ម៉ៅ សុផាន់** ជានាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២ មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

-+-+-

ព្រះរាជក្រឹត្យ នស/រកត/១១៩៧/២៦៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តម **ស៊ុយ ម៉ុងលាង** ជានាយកខុទ្ទកាល័យឯកឧត្តម **អ៊ឹង ហួត** នាយករដ្ឋមន្ត្រីទី១ ដោយមានឋានៈស្មើនឹង **រដ្ឋលេខាធិការ** ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ នស/រកត/១១៩៧/២៦៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងលោក **ណុ សម្បុរ** ជានាយកពិធីការ ឯកឧត្តម **អ៊ុង ហួត** នាយករដ្ឋមន្ត្រីទី១ ដោយមាន ឋានៈស្មើនឹង **អនុរដ្ឋលេខាធិការ** ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ នស/រកត/១១៩៧/២៦៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម
ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧៖

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងលោក **ម៉ាំ ជន** ជាទីប្រឹក្សា បន្ថែមលើមុខងារបច្ចុប្បន្ន ជានាយកខុទ្ទកាល័យ ឯកឧត្តម **អ៊ុង ហួត** នាយករដ្ឋមន្ត្រីទី១ ទទួលបន្ទុកកិច្ចការអប់រំ និងជាជំនួយការក្នុងការរៀបចំឯកសារ ដោយមានឋានៈស្មើនឹង **អនុរដ្ឋលេខាធិការ** ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គ

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

-++++

ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៧០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងលោក **គេន សុតិន** ជាទីប្រឹក្សាឯកឧត្តម **អ៊ុង ហួត** នាយករដ្ឋមន្ត្រីទី១ ទទួលបន្ទុកកិច្ចការអប់រំជាតិ ដោយមានឋានៈស្មើនឹង **អនុរដ្ឋលេខាធិការ** ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និង តាមព្រះរាជក្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

អនុក្រឹត្យលេខ៧៨ អនក្រ.បក
ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ
របស់ក្រសួងអភិវឌ្ឍន៍ជនបទ

※ ※ ※

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញ ព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្ដីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ អនុក្រឹត្យលេខ ២ប្រ.អនក្រ/បក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៨៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

-តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី១៦ ខែតុលា ឆ្នាំ ១៩៩៧

សំរេច

ជំពូក ១

បទបញ្ញត្តិទូទៅ

មាត្រា ១.- អនុក្រឹត្យនេះរៀបចំបណ្ដាអង្គភាព នៃក្រសួងអភិវឌ្ឍន៍ជនបទ និង កំណត់បេសកកម្មរបស់ក្រសួង និងមុខងារនៃអគ្គនាយកដ្ឋាន និងនាយកដ្ឋាននានា ។

ជំពូក ២

បេសកកម្ម និងរចនាសម្ព័ន្ធ

មាត្រា ២.- ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រងវិស័យអភិវឌ្ឍន៍ជនបទ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣.- ក្រសួងអភិវឌ្ឍន៍ជនបទមានមុខងារ និងភារកិច្ចដូចតទៅ :

-កំណត់នយោបាយ និង យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ជនបទស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។

-លើកទិសដៅផែនការរយៈពេលខ្លី មធ្យម វែង លើការងារអភិវឌ្ឍន៍ជនបទ ដើម្បីកែលំអស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌របស់ប្រជារាស្ត្រជនបទកាន់តែប្រសើរឡើង កាត់បន្ថយជាបណ្ដើរៗនូវភាពក្រីក្រ និងភាពខុសគ្នារវាងអ្នកជនបទ និងអ្នកទីក្រុង ។

-ចូលរួមក្នុងការកសាង និង អភិវឌ្ឍន៍ប្រទេសជាតិក្នុងវិស័យអភិវឌ្ឍន៍ជនបទ ដោយការិតសកម្មភាពការងារ ត្រឹមថ្នាក់គ្រួសារ ភូមិ និងឃុំ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

-សិក្សាស្រាវជ្រាវ ប្រមូលផ្ដុំ និងគ្រប់គ្រងទិន្នន័យ ពត៌មាន ស្ថិតិ អំពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៅតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជាដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

អភិវឌ្ឍធនធានមនុស្ស តាមរយៈការបណ្តុះបណ្តាលបច្ចេកទេសជំនាញ និងចំណេះដឹងដល់មន្ត្រី បុគ្គលិក រាជការរបស់ក្រសួង ។

-រៀបចំបើកមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈថ្នាក់ភូមិភាគដល់ប្រជារាស្ត្រជនបទតាមការចាំបាច់ និងតាមលទ្ធភាពជាក់ស្តែង ។

-អប់រំ ផ្សព្វផ្សាយ ដើម្បីលើកកំពស់ផលិតភាព និងប្រាក់ប្រចាំគ្រួសាររបស់ប្រជាពលរដ្ឋដោយផ្អែកលើការស្រាវជ្រាវបច្ចេកទេសជំនាញអភិវឌ្ឍន៍ជនបទ ។

-ធ្វើទំនាក់ទំនង សំរបសំរួល និងសហប្រតិបត្តិការជាមួយបរទេស អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នរដ្ឋ អាជ្ញាធរគ្រប់ជាន់ថ្នាក់ និងផ្នែកឯកជនដែលមានការពាក់ព័ន្ធព្រមទាំងប្រជារាស្ត្រមូលដ្ឋាន ដើម្បីធ្វើការអភិវឌ្ឍន៍ជនបទប្រកបដោយភាពស្ថិតស្ថេរយូរអង្វែង ។

-គ្រប់គ្រង ដឹកនាំ និងទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍន៍ជនបទចំពោះថ្នាក់គ្រួសារ ភូមិ ឃុំ ដែលរួមមានផ្លូវលំជនបទ ផ្គត់ផ្គង់ទឹកជនបទ ថែទាំសុខភាពបឋមអភិវឌ្ឍន៍សហគមន៍ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

-ជំរុញការរៀបចំ និង ពង្រឹងរចនាសម្ព័ន្ធអភិវឌ្ឍន៍ជនបទគ្រប់ជាន់ថ្នាក់ ជាពិសេសគណៈកម្មាធិការអភិវឌ្ឍន៍ជនបទនៅមូលដ្ឋាន ។

មាត្រា ៤.- ក្រសួងអភិវឌ្ឍន៍ជនបទ មានរចនាសម្ព័ន្ធដូចតទៅ :

-អគ្គាធិការដ្ឋាន

-អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

-អគ្គនាយកដ្ឋានបច្ចេកទេស

-ខុទ្ទកាល័យរដ្ឋមន្ត្រី

-អង្គភាពមូលដ្ឋាន

អង្គការលេខរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

ជំពូក ៣

អគ្គាធិការដ្ឋាន

មាត្រា ៥.- អគ្គាធិការដ្ឋានរបស់ក្រសួងអភិវឌ្ឍន៍ជនបទទទួលបន្ទុក :

-ធ្វើអធិការកិច្ចជាប្រចាំទៅលើគ្រប់អង្គភាព ក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ ។

-ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីពីការប្រព្រឹត្តិទៅរបស់អង្គភាព ដែលបានធ្វើអធិការកិច្ចរួចហើយ និង ពីមធ្យោបាយកែលំអការប្រព្រឹត្តិទៅរបស់អង្គភាពទាំងនោះ ។

-ប្រតិបត្តិភារកិច្ចតាមការដែលរដ្ឋមន្ត្រីបានប្រគល់ទំនុកចិត្ត ។

អធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូប និងអមដោយអគ្គាធិការរងជាជំនួយការ ។

ជំពូក ៤

អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

មាត្រា ៦.- អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ទទួលបន្ទុកធ្វើទំនាក់ទំនងសំរបសំរួល និងគ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក សម្ភារៈ បរិក្ខារ គណនេយ្យ ហិរញ្ញកិច្ច ផែនការ ស្ថិតិ តាមដាន និងវាយតំលៃសហប្រតិបត្តិការជាតិ និងអន្តរជាតិ ព្រមទាំងការងារបណ្តុះបណ្តាល ស្រាវជ្រាវ និង ផ្សព្វផ្សាយ ។ អគ្គនាយកដ្ឋានដឹកនាំដោយអគ្គនាយកមួយរូប និង រាចអមដោយអគ្គនាយករង ជាជំនួយការតាមការចាំបាច់ ។ អគ្គនាយកដ្ឋាននេះ មាននាយកដ្ឋានចំណុះចំនួន ៤ :

-នាយកដ្ឋានរដ្ឋបាល និង បុគ្គលិក

-នាយកដ្ឋានផ្គត់ផ្គង់ និង ហិរញ្ញវត្ថុ

-នាយកដ្ឋានផែនការ និង ទំនាក់ទំនងសាធារណៈ

-នាយកដ្ឋានបណ្តុះបណ្តាល និង ស្រាវជ្រាវ ។

មាត្រា ៧.- នាយករដ្ឋបាល និង បុគ្គលិកទទួលបន្ទុក :

-សំរបសំរួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និង រវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានក្រោមឱវាទក្រសួង ។

-រៀបចំរាល់លិខិតរដ្ឋបាល សំរាប់ការគ្រប់គ្រងអាជីព ។

-គ្រប់គ្រង និង ចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ។

-ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល ការពារសន្តិសុខ ថែរក្សាសណ្តាប់ធ្នាប់ និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង ។

-គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

-រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និង តារាងពត៌មានប្រតិបត្តិ ។

-ធ្វើកម្មវិធីពីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង ដោយទំនាក់ទំនងនឹងរដ្ឋលេខា-ធិការដ្ឋានមុខងារសាធារណៈ ។

-រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និងបន្ត ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង អនុវត្តនយោបាយនោះ ។

-លើកសំណើបង្កើត-រំសាយអង្គភាពនានា រៀបចំតួនាទីភារកិច្ច កែសំរួលរចនាសម្ព័ន្ធតាមស្ថានភាពជាក់ស្តែង តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

-គ្រប់គ្រងយានយន្តរបស់រដ្ឋ ដែលបំរើការងាររដ្ឋបាលនៅក្នុងក្រសួង ។

មាត្រា ៨.- នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុទទួលបន្ទុក:

-ប្រមូលផ្តុំតំរូវការ លើកគំរោងថវិកាក្រសួង ធ្វើកម្មវិធីចំណាយ និងតាមដានរំលឹកពីការប្រតិបត្តិ ។

-សំរបសំរួលជំពូកថវិកា និងរាល់ចំណាយរបស់ក្រសួង ។

-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ ។

-ធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ គ្រឿងបន្លាស់សំរាប់យានយន្តរបស់រដ្ឋ ដែលប្រគល់ជូនក្រសួង ។

-គ្រប់គ្រងការជួសជុលសំភារៈ និងបរិក្ខាររបស់ក្រសួង ។

-ទទួល និងបែងចែកបរិក្ខារជូនដល់បណ្តាអង្គភាពនានាក្រោមឱវាទក្រសួង ។

-កាន់បញ្ជីជាប្រចាំនូវសាលាកប័ត្រ និងគណនេយ្យរូបធាតុ ។

-គ្រប់គ្រងពត៌មានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី ។

-ត្រួតពិនិត្យបច្ចេកទេស នៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។

-គ្រប់គ្រងបន្ទុកគណនី របស់ការអនុវត្តលទ្ធកម្មសាធារណៈ ។

-តាមដានរំលឹកការគ្រប់គ្រងគណនីពិសេស ។

-ប្រមូលចំណូលឱ្យបានសមស្រប តាមច្បាប់ហិរញ្ញវត្ថុ ដែលបានកំណត់ ។

មាត្រា ៩.- នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈទទួលបន្ទុក :

-រៀបចំ ចងក្រង គ្រប់គ្រងប្រព័ន្ធទិន្នន័យ ស្ថិតិរបស់ក្រសួង និងលើកផែនការអភិវឌ្ឍន៍ជនបទរយៈពេលខ្លី មធ្យម និងយូរអង្វែងលើគ្រប់ផ្នែកទាំងអស់ ។

-ធ្វើកម្មវិធីសហប្រតិបត្តិការក្នុង និងក្រៅប្រទេសលើវិស័យអភិវឌ្ឍន៍ជនបទ ។

-សំរបសំរួលជំនួយពីបរទេស និងត្រួតពិនិត្យការអនុវត្តន៍ ។

-រៀបចំឯកសារ កិច្ចព្រមព្រៀង ឬ ពិធីសារនៃកិច្ចសហប្រតិបត្តិការ រវាងក្រសួងអភិវឌ្ឍន៍ជនបទជាមួយភ្នាក់ងារសហប្រជាជាតិ អង្គការអន្តរជាតិ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ។

-ណែនាំ ជំរុញ តាមដាន និងវាយតំលៃលើការអនុវត្តន៍ និងលទ្ធផលសំរេចបានលើផែនការដែលបានដាក់ចុះ ។

-ចូលរួមផ្តល់យោបល់ និងតាមដានវាយតំលៃលើការប្រើប្រាស់ទុនវិនិយោគ ក្នុងការអនុវត្តន៍ផែនការរដ្ឋ ។

-បូកសរុបរបាយការណ៍បច្ចេកទេស សេដ្ឋកិច្ច និងសង្គមកិច្ច គ្រប់ផ្នែកនៃវិស័យអភិវឌ្ឍន៍ជនបទ ។

-រៀបចំ និង បោះពុម្ពផ្សាយនូវព្រឹត្តិប័ត្រពត៌មានស្តីពីស្ថិតិ និង សកម្មភាពការងារសំរេចបាននៃគំរោងការងារអភិវឌ្ឍន៍ជនបទ ។

មាត្រា ១០.- នាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវទទួលបន្ទុក ;

-វាយតំលៃតំរូវការក្នុងការបណ្តុះបណ្តាល ។

-រៀបចំ លើកផែនការបណ្តុះបណ្តាល សិក្ខាសាលា ស្រាវជ្រាវ និងផ្សព្វផ្សាយរយៈពេលខ្លី មធ្យម និង យូរអង្វែង ។

- រៀបចំកម្មវិធីសំរាប់បណ្តុះបណ្តាលក្របខ័ណ្ឌ និងវិជ្ជាជីវៈទៅតាមតំរូវការជាក់ស្តែងនៃការហ្វឹកហ្វឺន ។
- បណ្តុះបណ្តាលចំណេះដឹង និងជំនាញដល់ក្របខ័ណ្ឌមន្ត្រី បុគ្គលិករាជការ ។
- បណ្តុះបណ្តាលវិជ្ជាជីវៈក្នុងមជ្ឈមណ្ឌល/សាលាហ្វឹកហ្វឺន ដល់តំណាង/ប្រជាកសិករជនបទ ដើម្បីបង្កើនមុខរបរចិញ្ចឹមជីវិត ។
- រៀបចំសិក្ខាសាលា/សន្និសីទ សំរាប់បង្កើនការយល់ដឹង និង ផ្លាស់ប្តូរបទពិសោធន៍ដល់មន្ត្រីបុគ្គលិក រាជការ និងប្រជាជន ។
- គ្រប់គ្រងមជ្ឈមណ្ឌលឯកសារ (បណ្ណាល័យ) របស់ក្រសួង និងមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈថ្នាក់ភូមិភាគ ។
- ស្រាវជ្រាវ ផ្នែកបច្ចេកវិទ្យាសមស្រប និងធ្វើពិសោធន៍លើគំរោងសំខាន់ៗ ។
- ផលិត និងចងក្រងឯកសារបច្ចេកទេស សេដ្ឋកិច្ច ដែលបានស្រាវជ្រាវ ដើម្បីជាមូលដ្ឋានសំរាប់ធ្វើការបណ្តុះបណ្តាល និងផ្សព្វផ្សាយ ។
- រៀបចំឯកសារ និង កម្មវិធីអភិវឌ្ឍន៍ជនបទ សំរាប់ផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និង ទស្សនាវដ្តី ដើម្បីរួមចំណែកឱ្យមានទូលាយក្នុងការបណ្តុះបណ្តាល អប់រំ និងឃោសនាពីខ្លឹមសារអត្ថប្រយោជន៍ សកម្មភាព និង សមិទ្ធផលនៃការងារអភិវឌ្ឍន៍ជនបទ សំរាប់ទាក់ទាញការចូលរួមកិច្ចសហប្រតិបត្តិការ និងការជួយឧបត្ថម្ភគាំទ្រពីសំណាក់ភ្នាក់ងារជាតិ អន្តរជាតិ ផ្នែកឯកជន ព្រមទាំងប្រជាពលរដ្ឋទូទៅ ។
- តាមដាន វាយតំលៃការងារបំពាក់បំប៉ន និងផ្សព្វផ្សាយ ។

ជំពូក ៥

អគ្គនាយកដ្ឋានបច្ចេកទេស

មាត្រា ១១.- អគ្គនាយកដ្ឋានបច្ចេកទេសទទួលបន្ទុកធ្វើផែនការ សំរបសំរួល និង គ្រប់គ្រងកម្មវិធី ផ្លូវលំជនបទ ផ្គត់ផ្គង់ទឹកជនបទ ថែទាំសុខភាពបឋម អភិវឌ្ឍន៍សហគមន៍ និង អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ។ អគ្គនាយកដ្ឋានដឹកនាំ ដោយអគ្គនាយកមួយរូប ដែលអាចមានអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។ អគ្គនាយកដ្ឋាននេះ មាននាយកដ្ឋានចំណុះចំនួន ៤ ដូចតទៅ :

-នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ

-នាយកដ្ឋានថែទាំសុខភាពជនបទ

-នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍

-នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

មាត្រា ១២.- នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទទទួលបន្ទុក :

-រៀបចំ លើកផែនការស្តារ និងអភិវឌ្ឍប្រព័ន្ធស្រោចស្រពខ្នាតតូចថ្នាក់គ្រួសារ ភូមិ ឃុំ ប្រព័ន្ធហាមពល តូចៗ ព្រមទាំងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និង ទឹកប្រើប្រាស់សំរាប់រយៈពេលខ្លី មធ្យម និងយូរអង្វែង ។

-សិក្សាស្រាវជ្រាវ លើកគំរោង និងជួសជុល សាងសង់ប្រព័ន្ធស្រោចស្រពខ្នាតតូចថ្នាក់គ្រួសារ ភូមិ ឃុំ ប្រព័ន្ធថាមពលតូចៗ ព្រមទាំងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងទឹកប្រើប្រាស់ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

-ត្រួតពិនិត្យគុណភាពទឹកអណ្តូង ដែលបានជីករួចមុននឹងដាក់ជូនប្រជាពលរដ្ឋមូលដ្ឋានប្រើប្រាស់ ។

-រៀបចំបែបបទ ដែលពាក់ព័ន្ធនឹងកិច្ចដំណើរការ និងថែទាំដោយប្រជាជននូវទឹកស្អាត ទឹកប្រើប្រាស់ និងទឹកស្រោចស្រពខ្នាតតូច ព្រមទាំងការរៀបចំសមាគម ឬ ក្រុមអ្នកប្រើប្រាស់ទឹកនៅជនបទ ។

មាត្រា ១៣.- នាយកដ្ឋានថែទាំសុខភាពជនបទទទួលបន្ទុក :

-រៀបចំ លើកផែនការថែទាំសុខភាពបឋមនៅតាមសហគមន៍ជនបទ សំរាប់រយៈពេលខ្លី មធ្យម និងយូរ អង្វែង ។

-បណ្តុះបណ្តាលចំណេះដឹង និង ជំនាញផ្នែកថែទាំសុខភាពបឋម និង អនាម័យដល់មន្ត្រីរាជការអភិវឌ្ឍន៍ជនបទ និងភ្នាក់ងារសុខភាពស្ម័គ្រចិត្តតាមភូមិ ។

-អប់រំសហគមន៍អំពីការថែទាំសុខភាពបឋម ដែលជាអាទិ៍រួមមានការអប់រំអំពីអាហារូបត្ថម ការគាំពារសុខភាពស្ត្រី ការលូតលាស់របស់កុមារ ការថែទាំសុខភាពផ្លូវចិត្ត និង ការការពារជំងឺផ្សេងៗ ។

-រៀបចំអនាម័យបរិស្ថានក្នុងភូមិ ដោយជួយឧបត្ថម្ភ និងបំផុសប្រជាជនចូលរួមក្នុងការសាងសង់បង្គន់អនាម័យតាមគ្រួសារ និងទីសាធារណៈ ព្រមទាំងអប់រំអ្នកភូមិឱ្យរស់អាតលំនៅឋាន និងប្រើប្រាស់ទឹកស្អាត ។

មាត្រា ១៤.- នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ទទួលបន្ទុក :

-រៀបចំ លើកផែនការអភិវឌ្ឍន៍សហគមន៍សំរាប់រយៈពេលខ្លី មធ្យម និងយូរអង្វែង ។

-សិក្សា ស្រាវជ្រាវ លើកគំរោង និងជួសជុល សាងសង់សំណង់ហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចជា ផ្លូវលំ ស្ពាន សាលារៀន មណ្ឌលសុខភាព ភូមិអភិវឌ្ឍន៍ ។ល។ តាមផែនការដែលបានដាក់ចុះ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

-សាងសង់ និងគ្រប់គ្រងមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ ។

-ជំរុញ និងលើកទឹកចិត្តប្រជាជនឱ្យបង្កើនការផលិតកម្មស្បៀង ដើម្បីផ្គត់ផ្គង់គ្រួសារ និងទីផ្សារ ។

-បញ្ជូនភ្នាក់ងារអភិវឌ្ឍន៍សហគមន៍ ចុះទៅតាមមូលដ្ឋានជនបទ ដើម្បីធ្វើការអប់រំឃោសនាផ្សព្វផ្សាយជូនប្រជាជន អំពីអក្ខរកម្ម ការការពារបរិស្ថាន និងធនធានធម្មជាតិ ព្រមទាំងការលើកទឹកចិត្តឱ្យដាំព្រៃឈើឡើងវិញ ការថែរក្សាប្រពៃណី វប្បធម៌ និងសីលធម៌ក្នុងការរស់នៅសិទ្ធិប្រជាពលរដ្ឋ លទ្ធិប្រជាធិបតេយ្យ បច្ចេកវិទ្យាសមស្របក្នុងដំណើរការផលិតកម្ម ការការពារគ្រោះថ្នាក់មីន ។ល។

-ចូលរួមជួយដោះស្រាយជូនជនមាតុភូមិនិវត្តន៍ និងជនផ្លាស់ប្តូរទីលំនៅ ។

-រៀបចំបែបបទ ដែលពាក់ព័ន្ធនឹងកិច្ចដំណើរការ និង ថែទាំដោយប្រជាជននូវហេដ្ឋារចនាសម្ព័ន្ធជនបទ ដើម្បីធានាឱ្យមានការអភិវឌ្ឍន៍ជនបទប្រកបដោយចីរភាព ។

-រៀបចំបែបបទក្នុងការបង្កើត ពង្រីក និងពង្រឹងរចនាសម្ព័ន្ធអភិវឌ្ឍន៍ជនបទ ជាពិសេសគណៈកម្មាការអភិវឌ្ឍន៍ភូមិ-ឃុំ ។

មាត្រា ១៥.- នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទទទួលបន្ទុក :

-រៀបចំ លើកផែនការសេដ្ឋកិច្ចជនបទ សំរាប់រយៈពេលវែង មធ្យម និងយូរអង្វែង ។

-រៀបចំគោលការណ៍ និងបំផុសប្រជាជនចូលរួមក្នុងការកសាងធនាគារភូមិ ធនាគារស្រូវ ធនាគារសត្វ ធនាគារសំភារៈកសិកម្ម ។

-រៀបចំបែបបទ ដែលពាក់ព័ន្ធនឹងការផ្តល់ទុនជូនប្រជារាស្ត្រខ្ចី ការចងក្រងសមាគមអ្នកផ្តល់ឥណទានផ្សេងៗ ។

-លើកទឹកចិត្តប្រជារាស្ត្រជនបទ អំពីការសន្សំប្រាក់តាមរយៈការផ្សព្វផ្សាយ ការរៀបចំក្រុមគណៈកម្មការសន្សំប្រាក់ ការណែនាំពីធានការក្សាការពារមូលនិធិសន្សំប្រាក់ ។

-គ្រប់គ្រង ណែនាំអំពីការរៀបចំបញ្ជីភាគណនេយ្យ សម្រាប់ការងារឥណទានជនបទ ។

-ជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋ សមាគម បផ្នែកឯកជនផ្សេងៗ ក្នុងការសាងសង់សហគ្រាស និងសិប្បកម្មតូចតាចនៅជនបទ ។

-ស្វែងយល់ និងទិតខំរកទីផ្សារ ដើម្បីដោះស្រាយចរាចរផលិតផល ដោយកំលែសអស្រប រួមចំណែកក្នុងការលើកស្ទួយកំរិតជីវភាពរស់នៅរបស់ប្រជាកសិករ និងសិប្បករនៅជនបទ ។

ជំពូក ៦

ខុទ្ទកាល័យរដ្ឋមន្ត្រី

មាត្រា ១៦.- ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបេសកកម្មទាំងឡាយ ដែលកំណត់តាមបទបញ្ញត្តិនៃអនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

ជំពូក ៧

អង្គភាពមូលដ្ឋាន

មាត្រា ១៧.- នៅតាមខេត្ត-ក្រុងនីមួយៗ មានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត-ក្រុងមួយ ដែលទទួលបន្ទុកអនុវត្ត និងសំរបសំរួលសកម្មភាពរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ។

ជំពូក ៨

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា ១៨.- អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ញាកំណត់ ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី១៦

វិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងមណ្ឌលក្រសួង ។

ជំពូក ៥

អវសានប្បញ្ញត្តិ

មាត្រា ១៩.- ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងនៅថ្នាក់កណ្ដាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ ។

មាត្រា ២០.- ការកំណត់ទាំងឡាយណា ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ស្ថាប័នដទៃ ប្រធានស្ថាប័ននៃស្ថាប័នដទៃទាំងនោះ និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវសហការគ្នា ដើម្បីបែងចែកការងារ ទទួលខុសត្រូវ និងអនុវត្តការងារនោះ តាមរយៈប្រកាសរួម របស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងប្រធានស្ថាប័នទាំងនោះ ។

មាត្រា ២១.- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រី និងផ្នែកលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ២៣.- អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋទី ២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

អនុក្រឹត្យលេខ ៧៩ អនក្រ.បក

ស្ដីពីការបង្កើតក្រុមដឹកនាំការងារកម្មវិធីសីលា

(SEILA TASK-FORCE)

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល កម្ពុជា ៖

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល កម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល កម្ពុជា

-តាមសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១.- បង្កើតក្រុមដឹកនាំការងារកម្មវិធីសីលា (SEILA TASK-FORCE) ដែលមានសមាសភាព ដូចខាងក្រោម ៖

១-ឯកឧត្ដម **គាត ឈន់** ទេសរដ្ឋមន្ត្រីទទួលបន្ទុកនីតិសម្បទា និងអភិវឌ្ឍន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — ប្រធាន

២-ឯកឧត្ដម **អ៊ឹម ឈុនលឹម** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ — អនុប្រធាន

៣-ឯកឧត្ដម **ឈា សុខ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ — សមាជិក

៤-ឯកឧត្ដម **ឌី ខិមហាត** អនុរដ្ឋលេខាធិការក្រសួងផែនការ — សមាជិក

៥- ឯកឧត្ដម **ទី ចាន់ផល** អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ — សមាជិក

៦- លោកជំទាវ **អ៊ឹម រុន** អនុរដ្ឋលេខាធិការកិច្ចការនារី — សមាជិក

៧- ឯកឧត្ដម **ឈៀវយ៉ាណារ៉ា** អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា — អគ្គលេខាធិការ

មាត្រា ២.- ក្រុមដឹកនាំកម្មវិធីសីលាមានភារកិច្ច ៖

-គ្រប់គ្រងពិនិត្យនិងវាយតម្លៃផែនការអភិវឌ្ឍន៍សាកល្បងរបស់កម្មវិធីសីលា ។

-សំរបសំរួលក្នុងការពិភាក្សាមញ្ញគោលនយោបាយជាតិ ដែលពាក់ព័ន្ធនឹងវិបជ្ជការ និងការអភិវឌ្ឍន៍ជនបទ ។

-ជាអាជ្ញាធរជាតិជាន់ខ្ពស់សំរាប់ដោះស្រាយ នូវអណត្តិនៃការអភិវឌ្ឍន៍ស្ថាប័ន និង វិស័យនានា ។

មាត្រា៣.- ស្ថាប័ននានាដែលនៅក្រោមក្រុមដឹកនាំការងារនេះ មានដូចខាងក្រោម :

១-គណៈកម្មាធិការអភិវឌ្ឍជនបទថ្នាក់ខេត្ត (គអជខៈ PRDC-Provincial Rural Development Committee) ដែលមានតួនាទីជាអ្នកវាយតម្លៃ និងធ្វើសេចក្តីសំរេចលើគំរោងវិនិយោគ និងដំណើការនៃកម្មវិធីសិលា ។ គអជខ មានលេខាធិការដ្ឋានសំរាប់ធាតុតែងគ្រប់គ្រង ការឧបត្ថម្ភវិបជ្ជការដល់ការអភិវឌ្ឍថ្នាក់ស្រុក ។

២-គណៈកម្មាធិការអភិវឌ្ឍន៍ថ្នាក់ស្រុក (គអសៈ DDC -District Development Committee) ដែលមានតួនាទីជាអ្នកជួយជំរុញ សំរួលនិងផ្តល់សេវា រាជរដ្ឋាភិបាលដល់សហគមន៍នានា ។

៣-គណៈកម្មាធិការអភិវឌ្ឍន៍ថ្នាក់ឃុំ (គអឃៈ CDC- Commune Development Commettee)ដែលមានតួនាទីជាអ្នកគ្រប់គ្រងថ្នាក់ឃុំលើកម្មវិធីសិលា ។

៤-គណៈកម្មាធិការអភិវឌ្ឍន៍ថ្នាក់ភូមិ(VDC-Village Development committee) ដែលមានតួនាទីជាអ្នកជួយជំរុញ និងសំរួលការចូលរួមរបស់ប្រជាជនភូមិក្នុងកម្មវិធីសិលា ។

មាត្រា ៤.- លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមដឹកនាំការងារកម្មវិធីសិលា ស្ថិតនៅទីស្នាក់ការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

មាត្រា៥.- ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម អស់លោកដូចមានឈ្មោះក្នុងមាត្រាទី១ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ឹង ហួត ហ៊ុន សែន

អនុក្រឹត្យលេខ ៨០ អនក្រ.បក
ស្តីពី
ប្រតិទិនឈប់សំរាកការងាររបស់មន្ត្រី
រាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ១៩៩៨

***

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

-បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៧៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញ អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់រយៈពេលឈប់ពីការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិលក្នុងព្រះរាជាណាចក្រកម្ពុជា

តាមសំណើរបស់គណៈអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ លេខ ១៨៥/៩៧ គបជអ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧

សំរេច

មាត្រា ១.- អនុញ្ញាតឱ្យមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជាទាំងអស់បានឈប់សំរាកការងារប្រចាំឆ្នាំ ១៩៩៨ តាមប្រតិទិនខាងក្រោម :

-ថ្ងៃទី ០១ មករា	ទិវាចូលឆ្នាំសកល	ចំនួន ០១ថ្ងៃ
-ថ្ងៃទី ០៧ មករា	ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍	ចំនួន ០១ថ្ងៃ
-ថ្ងៃទី ០៨ មីនា	ទិវានារីអន្តរជាតិ	ចំនួន ០១ថ្ងៃ
-ថ្ងៃទី ១៤-១៥-១៦ មេសា	ទិវាចូលឆ្នាំប្រពៃណីជាតិ	ចំនួន០៣ថ្ងៃ
ថ្ងៃទី ០១ ឧសភា	ទិវាពលកម្មអន្តរជាតិ	ចំនួន ០១ថ្ងៃ

-ថ្ងៃទី ១០ ឧសភា	បុណ្យពិសាខបូជា	ចំនួន ០១ថ្ងៃ
-ថ្ងៃទី ១៤ ឧសភា	ពិធីច្រត់ព្រះនង្គ័ល	ចំនួន ០១ថ្ងៃ
-ថ្ងៃទី ០១ មិថុនា	ទិវាកុមារអន្តរជាតិ	ចំនួន ០១ថ្ងៃ
-ថ្ងៃទី ១៨ មិថុនា	ព្រះរាជពិធីបុណ្យចំរើនព្រះជន្មវស្សាសម្តេចព្រះមហេសី នរោត្តម មនីនាថ សីហនុ	ចំនួន ០១ថ្ងៃ
-ថ្ងៃទី ២៤ កញ្ញា	ទិវាប្រកាសរដ្ឋធម្មនុញ្ញ និងព្រះរាជពិធីគ្រងរាជ្យសម្បត្តិជាថ្មីរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ	ចំនួន ០១ថ្ងៃ
-ថ្ងៃទី ១៩-២០-២១ កញ្ញា	បុណ្យភ្ជុំបិណ្ឌ	ចំនួន០៣ថ្ងៃ
-ថ្ងៃទី ២៣ តុលា	ទិវាសន្ធិសញ្ញាសន្តិភាពក្រុងប៉ារីស	ចំនួន ០១ថ្ងៃ
-ថ្ងៃទី៣០-៣១តុលានិង០១វិច្ឆិកា	ព្រះរាជពិធីបុណ្យចំរើនព្រះជន្មវស្សាព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ	ចំនួន០៣ថ្ងៃ
-ថ្ងៃទី ០២-០៣-០៤ វិច្ឆិកា	បុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក	ចំនួន០៣ថ្ងៃ
-ថ្ងៃទី ០៩ វិច្ឆិកា	បុណ្យឯករាជ្យជាតិ	ចំនួន ០១ថ្ងៃ
-ថ្ងៃទី ១០ ធ្នូ	ទិវាសិទ្ធិមនុស្ស	ចំនួន ០១ថ្ងៃ

មាត្រា ២.- ពេលវេលាឈប់ទាំងឡាយណា ដែលត្រូវចំថ្ងៃណាមួយ នៃថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ (ថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ) ត្រូវបានឱ្យឈប់សំរាកចំនួន ០១ថ្ងៃ នៃថ្ងៃបន្ទាប់ជាបន្ថែម [illegible] ។ ប៉ុន្តែក្នុងករណីត្រូវចំទាំង ០២ថ្ងៃ ជាប់គ្នាគឺទាំងថ្ងៃសៅរ៍ ទាំង[illegible]ត្យនេះ [illegible] ដែលត្រូវបានអនុញ្ញាតឱ្យឈប់បន្ថែមជំនួស គឺតែចំនួន ០១ថ្ងៃប៉ុណ្ណោះ ។

មាត្រា ៣.- បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ នៃគ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា

អ៊ុង ហួត **ហ៊ុន សែន**

អនុក្រឹត្យលេខ ២៣០ អនក្រ.តត

ស្តីពីការជូនមេដាយ ស្ថាបនាជាតិ

*****

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ស ំ រេ ច

មាត្រា ១.- ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិ ជូនឯកឧត្តម **ឡូ សុធីរៈ** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងអាគារសិក្សាមួយខ្នង ០២ ជាន់ ព្រមទាំងបរិក្ខារសិក្សា

គ្រប់គ្រាន់ចំណាយអស់ទឹកប្រាក់ចំនួន ១០០,០០០ដុល្លារអាមេរិក ផ្តល់ជូនដល់ប្រជារាស្ត្រក្រុងព្រះសីហនុ ។

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលក្រុងព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យបានទទួលលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា

អ៊ឹង ហួត **ហ៊ុន សែន**

អនុក្រឹត្យលេខ ២៣១ អនក្រ.តត

ស្តីពី

ការបំពាក់ឋានន្តរសក្តិជូនដល់នាយនគរបាលជាតិ

*****

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២

-បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រមលេខ នស.រកម.០១៩៦.០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១.- ត្រូវបានបំពាក់បានន្តរសក្តិថ្នាក់ វរសេនីយ៍ឯក ជូនដល់នាយនគរបាលជាតិ ចំនួន ២៦នាក់ ដូចមានរាយនាមខាងក្រោម :

១-លោក **យឹម សំណាង** អនុប្រធាននាយកដ្ឋានបុគ្គលិក

២-លោក **ទ្រាំ មឿន** អនុប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក

៣-លោក **ឈុន ឡុន** អនុប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក

៤-លោក **ប្រហ្ម ឧបចាន្ទី** អនុប្រធាននាយកដ្ឋាននគរបាលព្រំដែនទឹក

៥-លោក **ហម ច្រិច** អនុប្រធាននាយកដ្ឋានភស្តុភារ និងសំភារៈបច្ចេកទេស

៦-លោក **គីម សារ៉េន** អនុប្រធាននាយកដ្ឋានពត៏មានទូទៅ

៧-លោក **ស៊ីម សំបូរ** អនុប្រធាននាយកដ្ឋានសន្តិសុខសង្គម

៨-លោក **ទ្រាំ នាន** អនុប្រធាននាយកដ្ឋានកិច្ចការនគរបាល

៩-លោក **តុល គីមលី** អនុប្រធាននាយកដ្ឋានស្ថាបនា

១០-លោក **ហេង សុវណ្ណារិទ្ធ** អនុប្រធាននាយកដ្ឋានសុខាភិបាល

១១-លោក **ម៉ែន ទិបុល** អនុប្រធាននាយកដ្ឋាននាយកដ្ឋានសុខាភិបាល

១២-លោក **ខូច គីមឆាក់** ជំនួយការឯកឧត្តម ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

១៣-លោក **សម តារា** ជំនួយការឯកឧត្តម ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

១៤-លោក **ហ៊ុន ហៀន** ជំនួយការឯកឧត្តម ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

១៥-លោក ឌៀប សារាយ ជំនួយការឯកឧត្តម ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

១៦-លោក ហុង ម៉ុនហ៊ាង ជំនួយការឯកឧត្តម យូ ហុកគ្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

១៧-លោក ថាវ គឹមហេង ជំនួយការឯកឧត្តម យូ ហុកគ្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

១៨-លោក សំ គី ជំនួយការឯកឧត្តម យូ ហុកគ្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

១៩-លោក កែច ចណ្ណាថន ជំនួយការឯកឧត្តម ឯម សំអាន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

២០-លោក សុខ សុគំគ្រ ជំនួយការឯកឧត្តម ឯម សំអាន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

២១-លោក ពិន ពិសិដ្ឋ ជំនួយការឯកឧត្តម ឯម សំអាន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

២២-លោក ឃួរ ឡាមុនី ជំនួយការឯកឧត្តម ហុក ឡុងឌី អគ្គនាយកនគរបាលជាតិ

២៣-លោក សុត ថុល ជំនួយការឯកឧត្តម ហុក ឡុងឌី អគ្គនាយកនគរបាលជាតិ

២៤-លោក ទ្រាំ ឆា ជំនួយការឯកឧត្តម ហុក ឡុងឌី អគ្គនាយកនគរបាលជាតិ

២៥-លោក នឹង ម៉ុនធៀន ជំនួយការឯកឧត្តម ហុក ឡុងឌី អគ្គនាយកនគរបាលជាតិ

២៦-លោក ខ៊ាន សែត ជំនួយការឯកឧត្តម ហុក ឡុងឌី អគ្គនាយកនគរបាលជាតិ

មាត្រា២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី និងប្រធានស្ថាប័នពាក់ព័ន្ធ និងអស់លោកដែលមានឈ្មោះក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា

អ៊ឹង ហួត ហ៊ុន សែន

អនុក្រឹត្យលេខ ២៣២ អនក្រ.តត

ស្តីពីការជូនមេដាយ ស្ថាបនាជាតិ

*****

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១.- ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិ ជូនអង្គការ ASPECA ដែលបានជួយឧបត្ថម្ភគម្រោង ផ[illegible] យេសង្គមកិច្ច [illegible]សកុមារកំព្រា នៅក្នុងខេត្តបាត់ដំបង អស់ទឹកប្រាក់សរុបចំនួន ៦០.៧៧៥ $US។

មាត្រា២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ [illegible]ទី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យ[illegible] ្របានទទួលលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ឹង ហួត ហ៊ុន សែន

.....

អនុក្រឹត្យលេខ ២៣៣ អនក្រ.តត

ស្ដីពី

ស្ដីពីការតែងតាំងមន្ត្រីរាជការ

+++++

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២

-បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រីទី២

សំរេច

មាត្រា១. តែងតាំងលោក **ម៉ៅ ចន្ថា** ជាជំនួយការឯកឧត្ដម **ហោ ណាំហុង** ទីប្រឹក្សាសម្ដេចនាយករដ្ឋមន្ត្រីទី២ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន។**

មាត្រា២. សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន និងសាម៉ីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

អនុក្រឹត្យលេខ ២៣៤ អនក្រ.បក
ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ

*****

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-តាមសំណើរបស់អភិបាលខេត្តកំពង់ស្ពឺ

សំ រេ ច

មាត្រា ១.- ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិជូនលោក **ស្រី ទ្រី** ដែលបានបរិច្ចាគទ្រព្យធនផ្ទាល់ខ្លួនជួយកសាងអាគារសិក្សា វត្តអារាម ផ្លូវថ្នល់ និងអណ្ដូងទឹក នៅក្នុងឃុំ ជង្រុក ស្រុក គងពិសី ខេត្ត កំពង់ស្ពឺ អស់ទឹកប្រាក់សរុបប្រមាណ ២១.៨៩៦ SUS។

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទី[illegible] គណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យបានទទួលលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា

អ៊ឹង ហួត **ហ៊ុន សែន**

អនុក្រឹត្យលេខ ២៣៥ អនក្រ.តត
ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ

*****

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

សំរេច

មាត្រា ១.- ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិ តាមលំដាប់ថ្នាក់ជូនសប្បុរសជន ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលផ្សេងៗ នៅខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោមនេះ :

ក.-មេដាយស្ថាបនាជាតិ

១-អង្គការ **វើដឆាណា** កសាងអាគារសិក្សា ០៣ខ្នងនៅស្រុកបាធាយ អស់ទឹ[illegible]ាក់ ៣៧,៥០០ $US

២-ក្រុមហ៊ុនបារី MILD SEVEN កសាងរបងស្ដាតកំពង់ចាម អស់ទឹកប្រាក់ ៥៤,៥០[illegible]

៣-សាលាស្រុកកំពង់ចាម កសាងវេទិកា និងទូកងដាក់វត្ត សុទស្សនារាម [illegible] អស់ទឹកប្រាក់ ៧,៥០៥,៦០០រៀល និង ៩,១២[illegible]

៤-លោក **ជួន ឈឿន** និងភរិយា កសាងអាគារសិក្សាមួយ[illegible] សាលា[illegible] សូទិប ស្រុកជើងព្រៃ អ[illegible]ាក់ ២៨,០០០

ខ.មេដាយសិរីវឌ្ឍ ស្ថាបនាជាតិ :

១-លោក **លុយ ម៉ិនហេង** និងភរិយា កសាងសមិទ្ធិផលក្នុងស្រុកក្បូងឃ្មុំ អស់ទឹកប្រាក់ ២,០០៩ $US

២-លោក **សុខ ហេង** និងភរិយា កសាងសាលាស្រុកកំពង់ចាម អស់ទឹកប្រាក់ ១,៩០០ $US និង ៤,០៩០,០០០រៀល

៣-លោក **សែម ឆាន** កសាងផ្លូវ-សាលារៀន និងវត្តក្នុងស្រុកកំពង់ចាម អស់ទឹកប្រាក់ ៩,០០០,០០០ រៀល

៤-លោក **ឱុយ ម៉ាន់ឡើន** កសាងទូកង និងរោងទូកងក្នុងវត្តជ្រោយថ្ម អស់ទឹកប្រាក់ ២,៦៤១ $US

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យបានទទួលលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

